ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ២២ អនក្រ.បក

# **អនុក្រឹត្យ**
# **ស្តីពី**
# **ការកែសម្រួលតួនាទី ភារកិច្ចរបស់ នាយកដ្ឋានព័ត៌មានទូទៅ នៃក្រសួងមហាផ្ទៃ**

## **រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា១.-**

ត្រូវបានធ្វើការកែសម្រួល តួនាទី ភារកិច្ចរបស់នាយកដ្ឋានព័ត៌មានទូទៅ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ។ ការកែសម្រួលនេះ ក្នុងគោលបំណងដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារបម្រើអោយវិស័យ សន្តិសុខជាតិ សន្តិសុខសង្គម និងដើម្បីអោយសមស្របទៅនឹងសភាពការណ៍របស់ប្រទេសជាតិនាដំណាក់កាល បច្ចុប្បន្ន។

**មាត្រា២.-**

នាយកដ្ឋានព័ត៌មានទូទៅ មានតួនាទីធ្វើសេនាធិការជូនថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃលើការងារស្រាវជ្រាវ ប្រមូលព័ត៌មានចំហរ និងសំងាត់ ដែលពាក់ព័ន្ធដល់វិស័យសន្តិសុខជាតិ សំដៅរកអោយឃើញនូវសកម្មភាពអមិត្ត សកម្មភាពវិទ្ធង្សនាសង្គម សកម្មភាពល្មើសច្បាប់របស់រដ្ឋ អំពើភាវរកម្ម បទល្មើសឆ្លងដែន បទល្មើសជួញដូរផ្លូវភេទ ហិរញ្ញវត្ថុ និងសកម្មភាពមិនប្រក្រតីផ្សេងៗ ដើម្បីស្នើយោបល់ដល់ថ្នាក់ដឹកនាំ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃមានវិធានការ។

**មាត្រា៣.-**

នាយកដ្ឋានព័ត៌មានទូទៅ មានមុខងារ និងភារកិច្ចដូចខាងក្រោមៈ

- ស្រាវជ្រាវប្រមូលព័ត៌មានជាតិ អន្តរជាតិ ដើម្បីបម្រើដល់ការងារសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា ។
- ស្រាវជ្រាវប្រមូលព័ត៌មាន និងតាមដានការងារសន្តិសុខ និងការសំងាត់ជាតិតាមបណ្តាស្ថាប័ន ក្រសួង មន្ទីរ និងគ្រឹះស្ថានសាធារណៈរបស់រដ្ឋ។
- ស្រាវជ្រាវស៊ើបបញ្ជាក់ព័ត៌មាន តាមមធ្យោបាយឧបករណ៍បច្ចេកទេស និងកម្លាំងស៊ើបការ ដើម្បីប្រមូលភស្តុតាងបម្រើកិច្ចប្រតិបត្តិការជំនាញ និងការអនុវត្តច្បាប់។
- ត្រួតពិនិត្យបច្ចេកទេស បង្ក្រាបបទល្មើស និងហាមពលរដ្ឋខ្មែរចូលបនល្បែង ក្លឹបសំសាន្ត ក្លឹបផ្សងសំណាងស្របច្បាប់គ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា។
- សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីៈ
    - ពិនិត្យ តាមដានសកម្មភាពលើវិស័យអប់រំវប្បធម៌ សិល្បៈ ប្រព័ន្ធឃោសនា សេវាកម្ម ផលិតកម្ម ផ្សព្វផ្សាយចែកចាយព័ត៌មាន
    - ស្រាវជ្រាវប្រមូលព័ត៌មានតាមបណ្តាក្រុមហ៊ុន សហគ្រាស គ្រឹះស្ថានឯកជន និងបណ្តាអង្គការសហគមមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា
    - ត្រួតពិនិត្យប្រព័ន្ធប្រៃសនីយ៍ និងប្រព័ន្ធទូរគមនាគមន៍គ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ចូលរួមសហការស្រាវជ្រាវបង្ក្រាប និងដោះស្រាយនូវរាល់ករណីចាំបាច់ ដែលមានវិសាលភាពពាក់ព័ន្ធគ្រប់វិស័យដល់បណ្តាស្ថាប័ន ក្រសួងមន្ទីរ សហគម សាសនា និង ខេត្តក្រុង តាមបញ្ជាថ្នាក់លើ

- ទំនាក់ទំនងជាមួយបណ្ដាស្ថាប័ន ក្រសួងមន្ទីរ គ្រឹះស្ថាន សហគ្រាស អង្គការ សហគម និងអង្គភាពពាក់ព័ន្ធ ផ្ដល់នូវឯកសារ តួរលេខ និងព័ត៌មានផ្សេងៗតាមតំរូវការនៃវិធានការស្រាវជ្រាវរបស់ជំនាញនៃករណីនីមួយៗដែលថ្នាក់លើប្រគល់អោយ ដើម្បីបូកសរុបរាយការណ៍ជូនថ្នាក់លើពិនិត្យសំរេច
- សហការជាមួយបណ្ដាស្ថាប័នរដ្ឋ ឯកជន ដើម្បីកសាងបទដ្ឋាននិងលើកវិធានការការពារសន្ដិសុខសុវត្ថិភាពជូនឥស្សរជនសំខាន់ៗ និងតាមគោលដៅនីមួយៗ ។
- ប្រមូលព័ត៌មាន ស្ទាបស្ទង់មតិក្នុងសង្គមលើព្រឹត្តការណ៍សំខាន់ៗ ដើម្បីបូកសរុប វាយតម្លៃ សន្និដ្ឋានជូនថ្នាក់ដឹកនាំពិចារណា
- ទំនាក់ទំនង និងសហប្រតិបត្តិការជាមួយបណ្ដាប្រទេសនានា តាមគោលការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ដើម្បីផ្លាស់ប្ដូរព័ត៌មានជាមួយស្ថាប័នជំនាញ
- បូកសរុប វិភាគព័ត៌មាន ផ្ដើមសុំគោលការណ៍លើវិធានការជំនាញដើម្បីរាយការណ៍ជូនថ្នាក់លើ ពិនិត្យសម្រេច
- តាមដាន ត្រួតពិនិត្យណែនាំដល់នគរបាលខេត្ត ក្រុងអំពីវិធានការជំនាញដែលពាក់ព័ន្ធដល់កិច្ចប្រតិបត្តិការ ស្រាវជ្រាវប្រមូលព័ត៌មាន
- ធ្វើផែនការកសាងសមត្ថភាពធនធានមនុស្ស ទាំងជំនាញភាសាបរទេស និងបច្ចេកទេសវិទ្យាសាស្ត្រទូទៅ
- ប្រជុំដកពិសោធន៍ កែលម្អកិច្ចប្រតិបត្តិការ លើកកំពស់ប្រសិទ្ធភាពការងារដឹកនាំ និងពង្រឹងការអនុវត្តបទបញ្ជារបស់ថ្នាក់លើ
- ធ្វើការបូកសរុប គ្រប់គ្រងឯកសារ ការងារបុគ្គលិក គណនេយ្យ ភស្តុភាររបស់នាយកដ្ឋានតាមការកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់អោយ

**មាត្រា៤.–**

នាយកដ្ឋានព័ត៌មានទូទៅដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយ ។

**មាត្រា៥.–**

នាយកដ្ឋានព័ត៌មានទូទៅមានការិយាល័យមួយចំនួនចំណុះ។ ការរៀបចំ និងការប្រព្រឹត្តរបស់ការិយាល័យចំណុះនាយកដ្ឋានព័ត៌មានទូទៅ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៦.–**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៧.–**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ